ព្រះរាជក្រម

នស/រកម/១២១៧/០១៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

រដ្ឋសភា
ចូល លេខ ... ថ្ងៃទី ... ឆ្នាំ ... ម៉ោង ...
បញ្ជូនទៅ ...

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ នាសម័យប្រជុំពេញអង្គលើកទី១១ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •
ព្រះបរមរាជវាំង

# ច្បាប់

# ស្តីពី

# ហិរញ្ញវត្ថុសម្រាប់

# ការគ្រប់គ្រងឆ្នាំ២០១៨

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ជំពូកទី១

## ថវិកាថ្នាក់ជាតិ

**មាត្រា១ .-**

ត្រូវបានអនុញ្ញាតសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ឱ្យប្រមូលចំណូលបង់ចូលថវិកាថ្នាក់ជាតិនូវពន្ធដារ វិភាគទាន អាករ ផលទុន និងចំណូលនានា ព្រមទាំងធ្វើឱ្យសម្រេចនូវឧបត្ថម្ភធនវិនិយោគនិងការខ្ចីតាមមាតិកាថវិកា ដូចមានចែងក្នុងតារាង "**ត១**" ដែលភ្ជាប់មកជាមួយច្បាប់នេះ ក្នុងទឹកប្រាក់សរុបចំនួន២២ ៤៣៧ ១៣៨លានរៀល ដែលត្រូវបានបែងចែកដូចតទៅ ៖

- ចំណូលចរន្ត...................................................... ១៧ ៤៦០ ០០៦លានរៀល
- ចំណូលមូលធន...............................................៤ ៩៧៧ ១៣២លានរៀល
  - \+ ចំណូលមូលធនក្នុងប្រទេស..................................១៨០ ១៩៣លានរៀល
  - \+ ចំណូលមូលធនក្រៅប្រទេស.............................៤ ៧៩៦ ៩៣៩លានរៀល
    - មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ
      ..............................................................២៥០ ០០០លានរៀល
    - វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស
      ...................................................៤ ៥៤៦ ៩៣៩លានរៀល។

**មាត្រា២ .-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានចំណាយថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ត្រូវបានកំណត់ស្មើនឹង២៣ ៤២៨ ២៩៨លានរៀល ដែលត្រូវបានបែងចែកដូចតទៅ ៖

- ចំណាយចរន្ត.................................................. ១៥ ២១៨ ១៦៦លានរៀល
- ចំណាយមូលធន.............................................៨ ២១០ ១៣២លានរៀល

ក- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស

...................................................................... ២ ៩២៥ ៨០០លានរៀល

- ដោយថវិកាថ្នាក់ជាតិ................................២ ៦៧៥ ៨០០លានរៀល
  - គម្រោងវិនិយោគផ្ទាល់................២ ០៧៥ ៨០០លានរៀល

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

▪ បដិភាគក្នុងការអនុវត្តគម្រោងហិរញ្ញប្បទានក្រៅប្រទេស
................................................ ៦០០ ០០០លានរៀល

- ដោយមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ
................................................................. ២៥០ ០០០លានរៀល

ខ- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

.....................................................................៤ ៥៤៦ ៩៣៩លានរៀល

គ- ការទូទាត់ការខ្ចី.............................................៧៣៧ ៣៩៣លានរៀល។

**មាត្រា៣** ._

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានចំណាយចរន្តថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ត្រូវបានកំណត់ស្មើនឹង១៥ ២១៨ ១៦៦លានរៀល។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ និងទៅតាមប្រភេទចំណាយ ដូចមានចែងក្នុងតារាង "**ខ១**" ដែលភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា៤** ._

ចំនួនទឹកប្រាក់នៃឥណទានចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស សម្រាប់ការគ្រប់គ្រងពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២០ ត្រូវបានកំណត់ស្មើនឹង២១ ៣៤១ ៥៩៨លានរៀល។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗតាមគម្រោងនិងតាមឆ្នាំ ដូចមានចែងក្នុងតារាង "**គ១**" ដែលភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា៥** ._

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានភ្ជាប់សន្យា និងឥណទានទូទាត់សម្រាប់ចំណាយមូលធនថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ត្រូវបានកំណត់ដូចខាងក្រោម ៖

- ឥណទានភ្ជាប់សន្យា................................ ៨ ២១០ ១៣២លានរៀល
- ឥណទានទូទាត់.................................... ៨ ២១០ ១៣២លានរៀល។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

ឥណទាននេះត្រូវបានបែងចែកដូចតទៅ ៖

ក. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស

- ឥណទានភ្ជាប់សន្យា...............................២ ៩២៥ ៨០០លានរៀល
- ឥណទានទូទាត់......................................២ ៩២៥ ៨០០លានរៀល

ខ. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

- ឥណទានភ្ជាប់សន្យា.............................. ៤ ៥៤៦ ៩៣៩លានរៀល
- ឥណទានទូទាត់..................................... ៤ ៥៤៦ ៩៣៩លានរៀល

គ. ការទូទាត់ការខ្ចី

- ឥណទានភ្ជាប់សន្យា..................................៧៣៧ ៣៩៣លានរៀល
- ឥណទានទូទាត់.......................................៧៣៧ ៣៩៣លានរៀល។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗដូចមានចែងក្នុងតារាង "**គ២**" និង "**ឃ**" ដែលភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា៦** .-

តុល្យភាពនៃថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ដែលបានរៀបចំនៅក្នុងតារាង "**ក១**" ស្តីពីចំណូលថវិកាថ្នាក់ជាតិ និងតារាង "**ខ១**" ស្តីពីចំណាយថវិកាថ្នាក់ជាតិត្រូវបានបង្ហាញនៅក្នុងតារាងកិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិដូចខាងក្រោម ៖

